NGO-CEDAW

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បី
អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

គណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW)

ADHOC
AMARA
AR
BSO
BWAP
CCFC
CADEA
CADPP
CAMBOW
CCIM/VOD
CCPCR
CD Cam
CDP
CDWN
CDPO
CFSWF
CHEC
CLEC
CLC
CICA
CMH
CODO
COSECAM
CPWP
CSD
CYN
CUMA
CWCC
CWDA
CWMO
CWPD
DAC
EDCO
FAA
GAD/C
GGAC
IDA
IDEA
HIPPO
KFDA
KHEMARA
KWCD
KWVC
KYA
LAC

# សេចក្តីថ្លែងការណ៍រួម
# ទិវាសិទ្ធិនារីអន្តរជាតិ
# ថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០១៤

NGO-CEDAW និង CAMBOW ជាសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដែលធ្វើសកម្មភាព ដើម្បីភាពរីកចម្រើននៃសិទ្ធិរបស់ស្ត្រី ព្រមទាំងធ្វើការឃ្លាំមើលនូវការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) យើងខ្ញុំសូមអំពាវនាវដោយទទូចដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យអនុវត្តនូវសេចក្តីអង្កេតសន្និដ្ឋាន (អនុ-សាសន៍) ដែលចេញដោយគណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុក CEDAW សម្រាប់ប្រទេសកម្ពុជា កាលពីថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ កន្លងទៅនេះ។

ចាប់តាំងពីពីខែ មករា ឆ្នាំ ២០១៤ មក មានការបង្ក្រាបដោយប្រើហិង្សា ទៅលើបាតុកម្មអហិង្សា ដែលរៀបចំឡើងដោយក្រុមកម្មករ-កម្មការនីរោងចក្រកាត់ដេរ និងក្រុមស្ត្រីសកម្មជនដីធ្លី នៅក្នុងរាជធានីភ្នំពេញ។ កាលពីថ្ងៃទី ២ និងទី ៣ ខែ មករា កងកម្លាំងប្រដាប់អាវុធ បានវាយបំបែកក្រុមកម្មករ ដែលបណ្តាលឲ្យមានមនុស្សស្លាប់យ៉ាងតិច ៤ នាក់ និង រងរបួល ៤០ នាក់ ផ្សេងទៀត។ នៅក្នុងព្រឹត្តិការណ៍បង្ក្រាបនេះ មានមនុស្សចំនួន ២៣ នាក់ ត្រូវបានចាប់ខ្លួន រួមមាន កម្មករ ថ្នាក់ដឹកនាំសហជីព និងសកម្មជនដីធ្លី។ ក្រោយមកបានធ្វើការដោះលែងមនុស្សចំនួន ២ នាក់ ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែមនុស្សចំនួន ២១ នាក់ទៀតនៅបន្តឃុំខ្លួននៅក្នុងមណ្ឌលកែប្រែ ម៣ នៅឡើយ ដែលអ្នកទាំងនោះកំពុងស្ថិតក្នុងស្ថានភាពភ័យតក់ស្លត់យ៉ាងខ្លាំង។ នៅក្នុងចំណោមអ្នកទាំង ២១ នាក់នេះ មានពីរនាក់ជាជាសមាជិក NGO-CEDAW និង CAMBOW រួមមាន លោក វ៉ន ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) និង លោក ថេង សាវឿន មន្ត្រីសម្របសម្រួលនៃសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) ។

LICADHO
LSCW
ML&NV
NAPA
NEP
NGO Forum
NICFEC
OI
PCC
RHB
SILAKA
SK
SSC
VAWCC
VYCD
WDA
WFP
WHIAD
WMC
WOSO
YRDP

ការបង្ក្រាបជាបន្តបន្ទាប់ និងការដាក់បំរាមមិនឲ្យមានការប្រមូលផ្តុំ ពីសំណាក់រដ្ឋាភិបាលកម្ពុជា បង្ហាញថារដ្ឋាភិបាលមិនកំពុងអនុវត្តនូវបទដ្ឋាន និងច្បាប់នានាស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងរួមទាំងអនុសញ្ញាCEDAW និង សេចក្តីអង្កេតសន្និដ្ឋាន(អនុសាសន៍) របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុក CEDAW នោះឡើយ។

NGO-CEDAW និង CAMBOW សូមអំពាវនាវដោយទទូច ឲ្យធ្វើការដោះលែងមនុស្សទាំង ២១ នាក់ដែលកំពុងឃុំខ្លួននៅមណ្ឌលកែប្រែ ម៣ ជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ។ ជាពិសេសសូមឲ្យរដ្ឋាភិបាល គោរពតាមការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលអនុវត្តនូវអនុសញ្ញា CEDAW និង សេក្តីអង្កេតសន្និដ្ឋាន របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកអនុសញ្ញា CEDAW។

ធ្វើនៅភ្នំពេញ ថ្ងៃទី៨ ខែមីនា ឆ្នាំ ២០១៤

សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនង:

NGO-CEDAW

-កញ្ញា **អ៊ូ ទេពផល្លីន** លេខទូរស័ព្ទ:០១១៩៨៩៨៨៣/០៩៨៩៨៩៨៨៣

Email: phallin@cfswf.org

-លោក **ហេង សំអ៊ិន**លេខទូរស័ព្ទ:០១៥៧៧០១២០ Email: orn_idea@yahoo.com

CAMBOW

-លោកបណ្ឌិត **ហាង្ស ពុទ្ធា** លេខទូរស័ព្ទ: ០១២ ៩៥៩ ៦៦៦ Email: puthea2@gmail.com

-កញ្ញា **នៅ ស្រីអូន** លេខទូរស័ព្ទ: ០៧៧ ៧២២ ៧២៥ Email: novsreyaun@yahoo.com